ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 18 / 02 / 2016
ម៉ោង (Time/Heure) : 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E319/32/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦

**ផ្ញើជូន៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយទាក់ទងនឹងការប្រព្រឹត្តិចំពោះជនជាតិចាម អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤)

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកជាឯកសារភ័ស្តុតាង នូវកំណត់ហេតុនៃការស្តាប់ចម្លើយទាក់ទងនឹងការប្រព្រឹត្តិចំពោះជនជាតិចាម អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) ដែលបានដាក់នៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៥ ("សំណើ" ឯកសារ E319/32)។ ចម្លើយទាំងនោះ ដែលត្រូវបានកំណត់អត្តសញ្ញាណបន្ថែមនៅក្នុងតារាងឧបសម្ព័ន្ធនៃសំណើនេះ (*សូមមើល* ឧបសម្ព័ន្ធ I ឯកសារ E319/32.1) គឺជាការស្តាប់ចម្លើយសាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីដែលបានធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត នៅក្នុងសំណុំរឿង ០០៣ និង ០០៤ ហើយបន្ទាប់មកត្រូវបានដាក់

បង្ហាញនៅក្នុងសំណុំរឿង ០០២/០២។ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា ចម្លើយទាំងនេះជាប់ពាក់ព័ន្ធទៅនឹងការធ្វើទុក្ខបុកម្នេញ និង ការសម្លាប់ប្រជាជនចាមនៅតាមស្រុកនានានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ(ឯកសារ E319/32 កថាខណ្ឌ១ ដល់ ៣)។ សហព្រះរាជ-អាជ្ញាអន្តរជាតិលើកឡើងបន្ថែមទៀតថា សំណើបានដាក់ទាន់ពេលវេលាដោយសារចម្លើយទាំងនោះមិនអាចរកបានមុនពេលចាប់ផ្តើមការជំនុំជម្រះ (ឯកសារ E319/32 កថាខណ្ឌ ៤)។

២. នៅថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ បន្ទាប់ពីមានសំណើផ្ទាល់មាត់មួយពីមេធាវីការពារក្តី ខៀវ សំផន អង្គជំនុំជម្រះបានសម្រេចផ្តល់ពេលវេលាបន្ថែមឱ្យភាគី ក្នុងការឆ្លើយតបទៅនឹងសំណើបន្ទាប់ពីអង្គជំនុំជម្រះបានចេញសេចក្តីសម្រេចមួយលើសំណើ E363។ (*សូមមើល* ប្រតិចារឹកសវនាការថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ទំព័រ ៣ ដល់ ៦, ១៩)។ បន្ទាប់មក សារណាតបផ្ទាល់មាត់ត្រូវបានកំណត់ពេលធ្វើនៅថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥ (សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៥)។ មេធាវីការពារក្តី នួន ជា មិនបានធ្វើសារណាឆ្លើយតបនោះទេ។ មេធាវីការពារក្តី ខៀវ សំផន បានជំទាស់ទៅនឹងការទទួលយកឯកសារចំនួន ២២ ក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយដែលបានស្នើសុំ ប៉ុន្តែមិនបានជំទាស់ទៅនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយដែលមានចុះលេខ ៤, ២ និង ១៩ នៅក្នុងឧបសម្ព័ន្ធ I ទេ ពោលគឺឯកសារ E319/13.3.17, E319/28.3.1 និង E319/19.3.95។ មេធាវីការពារក្តីលើកឡើងថាកំណត់ហេតុស្តាប់ចម្លើយដែលមានលេខឯកសារ E319/13.3.17 ត្រូវបានទទួលយកជាឯកសារភ័ស្តុតាងរួចហើយ ចំណែកឯកំណត់ហេតុស្តាប់ចម្លើយដែលមានលេខឯកសារ E319/28.3.1 គឺពាក់ព័ន្ធនឹងសាក្សីម្នាក់ដែលបានមកផ្តល់សក្ខីកម្មរួចហើយ និងកំណត់ហេតុស្តាប់ចម្លើយដែលមានលេខឯកសារ E319/19.3.95 គឺពាក់ព័ន្ធនឹងសាក្សីម្នាក់ទៀតដែលត្រូវបានរំពឹងថានឹងមកផ្តល់សក្ខីកម្មនាពេលឆាប់ៗខាងមុខ (ប្រតិចារឹកសវនាការថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥ ទំព័រ ៣៥ ដល់ ៣៦)។ អង្គជំនុំជម្រះកត់សម្គាល់ថា សាក្សីចុងក្រោយនេះ គឺសាក្សី 2-TCW-988 (សយ ឡើន) ដែលបានមកផ្តល់សក្ខីកម្មរួចហើយ កាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៦។

៣. មេធាវីការពារក្តី ខៀវ សំផន ជំទាស់ទៅនឹងការទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយដែលនៅសេសសល់ចំនួន ២២ ទៀត ដោយផ្អែកលើមូលដ្ឋានថា ឯកសារទាំងនេះមិនស្រប

តាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងវិធាន ៨៧(៣) និង ៨៧(៤) ទេ។ មេធាវីការពារក្ដីលើកឡើងថា (ប្រតិចារឹកសវនាការថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥ ទំព័រ ៣៦ ដល់ ៤០) ៖

ក. វិធាន ៨៧(៤) ជាវិធានលើកលែង និង គួរត្រូវបានកំហិតត្រឹមតែភស្តុតាងដែលជាប់ពាក់ព័ន្ធទៅនឹងការស្វែងរកការពិត។

ខ. ការទទួលយកចម្លើយជាទម្រង់នៃកំណត់ហេតុនៃការស្តាប់ចម្លើយ ជំនួសឱ្យការស្តាប់សក្ខីកម្មផ្ទាល់មាត់មិនអនុញ្ញាតឱ្យមានការសួរដេញដោលទៅលើខ្លឹមសារនៃចម្លើយទាំងនោះទេ ហេតុនេះ តម្លៃភស្តុតាងតិចតួចណាស់ដែលគួរផ្តល់ដល់ឯកសារទាំងនោះ។

គ. សហព្រះរាជអាជ្ញាអន្តរជាតិមិនបានបង្ហាញថា ចម្លើយទាំងនោះមានសារៈសំខាន់ក្នុងការទទួលយកដើម្បីជាប្រយោជន៍យុត្តិធម៌ទេ។

ឃ. សហព្រះរាជអាជ្ញាអន្តរជាតិមិនបានបំពេញការងារដោយយកចិត្តទុកដាក់ ដោយដាក់សំណើមិនបានទាន់ពេលវេលា ពោលគឺបន្ទាប់ពីការជំនុំជម្រះលើផ្នែកនៃការប្រព្រឹត្តិចំពោះជនជាតិចាមបានចាប់ផ្តើមធ្វើហើយ នៅពេលដែលសហព្រះរាជអាជ្ញាអន្តរ-ជាតិគួរតែបានដឹងតាំងពីមុនម្ល៉េះ ពីភាពជាប់ពាក់ព័ន្ធនៃចម្លើយទាំងនោះ។

ង. សំណើគឺមិនស្របទៅនឹងសេចក្តីសន្និដ្ឋាន និង ការណែនាំនៃសេចក្តីសម្រេចក្នុងឯកសារ E363/3 ដែលអង្គជំនុំជម្រះបានសន្និដ្ឋានថា មានតែករណីលើកលែងប៉ុណ្ណោះដែលភស្តុតាងដែលមិនស្របទៅនឹងលក្ខណៈវិនិច្ឆ័យនៃវិធាន ៨៧(៤) ត្រូវអាចទទួលយកបាន។

ច. ចម្លើយទាំងនោះមានលក្ខណៈច្រំដែល ដោយសារអង្គជំនុំជម្រះសាលាដំបូងមានភស្តុ-តាងជាលាយលក្ខណ៍អក្សរ និង ផ្ទាល់មាត់គ្រប់គ្រាន់ហើយ ពាក់ព័ន្ធនឹងការប្រព្រឹត្តិចំពោះជនជាតិចាម រួមទាំងប្រធានបទផ្សេងៗទៀតផងដែរ ហើយការទទួលយកភស្តុតាងថ្មីៗនៅដំណាក់កាលនេះ នឹងបណ្តាលឱ្យមានការផ្ទុកច្រើនហួសហេតុនៅក្នុងសំណុំរឿងដែលជាការមិនចាំបាច់។ និង

ឆ. សំណើសុំឱ្យទទួលយកចម្លើយលេខ ១១ និង ១២ ក្នុងឧបសម្ព័ន្ធ I ពោលគឺឯកសារ E319/19.3.219 និង E319/19.3.93 ជាការឆាប់រហ័សពេក ដោយសារអង្គជំនុំជម្រះមិនទាន់បានសម្រេចលើការជំទាស់របស់មេធាវីការពារក្តី ខៀវ សំផន ចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះក្នុងការកោះហៅសាក្សី 2-TCW-987 នៅឡើយទេ (*សូមមើល* ឯកសារ E364)។

៤. សហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតបវិញថា កំណត់ហេតុនៃការស្តាប់ចម្លើយទាំងអស់ស្របទៅនឹងលក្ខណៈវិនិច្ឆ័យនៃវិធាន ៨៧(៤) និងបានអះអាងជាថ្មីថា ការបំពេញការងារដោយយកចិត្តទុកដាក់ត្រូវបានអនុវត្ត ក្នុងការនាំយកកំណត់ហេតុស្តាប់ចម្លើយនីមួយៗមកដាក់ជូនអង្គជំនុំជម្រះពិចារណាបានទាន់ពេលវេលា។ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា អនុលោមតាមសេចក្តីសម្រេចនៅក្នុងឯកសារ E363/3 ភស្តុតាងពីសំណុំរឿង ០០៣ និង ០០៤ ត្រូវបានចាត់ទុកថា ពុំអាចរកបានតាមគោលបំណងនៃវិធាន ៨៧(៤) រហូតដល់ពេលដែលការិយាល័យសហចៅក្រមស៊ើបអង្កេតអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាផ្តល់ភស្តុតាងនេះដល់ភាគីនៅក្នុងសំណុំរឿង ០០២/០២ និងកត់សម្គាល់ថា ចម្លើយទាំងនេះត្រូវបានអនុញ្ញាតឱ្យដាក់បង្ហាញក្នុងអំឡុងពេលពី ខែ កុម្ភៈ ដល់ខែ សីហា ឆ្នាំ ២០១៥ (ប្រតិចារឹកសវនាការថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥ ទំព័រ ៤០ ដល់ ៤៣)។

៥. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នៅគ្រប់ដំណាក់កាលនៃការជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង អាចទទួលយកភស្តុតាងទាំងអស់ដែលខ្លួនយល់ថាមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត (ឯកសារ E319/7 កថាខណ្ឌ ៨)។ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចលើសំណើសុំឱ្យទទួលយកភស្តុតាងថ្មី ផ្អែកតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងវិធាន ៨៧(៣)។ វិធាន ៨៧(៤) ក៏តម្រូវផងដែរថា គ្រប់ភាគីដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ ភាគីដែលស្នើសុំត្រូវតែធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថាសក្ខីកម្ម ឬ ភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ ឬ មិនអាចរកបានបន្ទាប់ពីបានបំពេញការងារដោយយកចិត្តទុកដាក់ហើយក៏ដោយ។ ទោះជាយ៉ាងណាក្តី នៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះបានទទួលយកភស្តុតាងដែលមិនបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យនេះទាំងស្រុងទេ រួមមាន ក្នុងករណីដែល

ភស្តុតាងពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងសម្ភារៈដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ ហើយផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យប្រភពទាំងនោះត្រូវធ្វើការវាយតម្លៃរួមគ្នា នៅពេលដែលភស្តុតាងដែលបានស្នើឡើងជាភស្តុតាងដោះបន្ទុក និង តម្រូវឱ្យមានការវាយតម្លៃដើម្បីបញ្ចៀសនូវកំហុសក្នុងការស្វែងរកយុត្តិធម៌ ឬ នៅពេលដែលភាគីផ្សេងទៀតមិនបានជំទាស់ទៅនឹងភស្តុតាងនោះ (ឯកសារ E276/2 កថាខណ្ឌ ២ ដោយយោងដល់ឯកសារ E190 និង E172/24/5/1)។

៦. អង្គជំនុំជម្រះសាលាដំបូងរម្លឹកឡើងវិញបន្ថែមទៀតទៅដល់សេចក្ដីសម្រេចរបស់ខ្លួន ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥ ទាក់ទងនឹងកាតព្វកិច្ចនៃការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញា ដែលអង្គជំនុំជម្រះបានកម្រិតការដាក់បង្ហាញនាពេលខាងមុខ ត្រឹមភស្តុតាងដោះបន្ទុក និង ចម្លើយរបស់បុគ្គលដែលបានផ្ដល់សក្ខីកម្មរួចហើយ ឬ បុគ្គលដែលត្រូវបានស្នើសុំកោះហៅឱ្យមកផ្ដល់សក្ខីកម្ម។ អង្គជំនុំជម្រះបានបញ្ជាក់នៅក្នុងសេចក្ដីសម្រេចនេះថា ការទទួលយកជាភស្តុតាងដែលមិនស្ថិតក្នុងប្រភេទទាំងនេះ នៅតែអាចស្នើសុំបានតាមវិធាន ៨៧(៤) (ឯកសារ E363/3 កថាខណ្ឌ ៣៦)។

៧. ចាប់តាំងពីដំបូងមក អង្គជំនុំជម្រះកត់សម្គាល់ថា សំណើពាក់ព័ន្ធនឹងចម្លើយដែលមានលេខឯកសារ E319/28.3.1 និង E319/13.3.17 (លេខ ២ និង ៤ នៅក្នុងឧបសម្ព័ន្ធ I) ទុកជាអាសារបង់ ដោយសារឯកសារទាំងនេះត្រូវបានទទួលយកជាភស្តុតាង និងត្រូវបានចុះលេខជាឯកសារ E3/9649 និង E3/9580 រួចហើយ (សូមមើល ឯកសារ E373 ឧបសម្ព័ន្ធ I, ប្រតិចារឹកសវនាការថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ ទំព័រ ១២ ដល់ ១៤ ឯកសារ E1/353)។ បន្ថែមពីលើនេះទៀត ឯកសារ E319/19.3.93 (លេខ ១២ នៅក្នុងឧបសម្ព័ន្ធ I) ត្រូវបានដាក់ចំពោះមុខអង្គជំនុំជម្រះរួចហើយ ដោយសហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងអំឡុងពេលសួរដេញដោលសាក្សី 2-TCW-987 ដោយមិនមានភាគីណាមួយជំទាស់នោះទេ ហើយបន្ទាប់មកឯកសារនោះត្រូវបានទទួលលេខ E3/9659 (*សូមមើល* ប្រតិចារឹកសវនាការថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១០, ១២, ១៤, ១៩, ២០, ២៨, ៣២, ៣៣, ៣៧, ៥៣)។ ចម្លើយដែលមានលេខឯកសារ E319/19.3.226 (លេខ ២១ នៅក្នុងឧបសម្ព័ន្ធ I) ត្រូវបានទទួលយកជាឯកសារភស្តុតាង អនុលោមតាមសេចក្ដីសម្រេចផ្ទាល់មាត់មួយរបស់អង្គជំនុំជម្រះ នៅថ្ងៃទី

១២ ខែ មករា ឆ្នាំ ២០១៦ ដែលសំអាងហេតុនឹងចេញនៅពេលក្រោយ (*សូមមើល* ប្រតិចារឹកសវនា-ការថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ៤៦ ដល់ ៤៧)។ អង្គជំនុំជម្រះកត់សម្គាល់ថា ចម្លើយ E319/19.3.226 មិនអាចរកបានមុនពេលចាប់ផ្ដើមការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២។ កំណត់ហេតុស្ដាប់ចម្លើយនេះត្រូវបានដាក់បង្ហាញដោយសហព្រះរាជអាជ្ញាអន្តរ-ជាតិ នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៥ បន្ទាប់ពីការិយាល័យសហចៅក្រមស៊ើបអង្កេតបានអនុញ្ញាតឱ្យដាក់បង្ហាញនៅថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៥ (សំណុំរឿង ០០៤-D193/15)។ ដោយពិចារណាថា កំណត់ហេតុស្ដាប់ចម្លើយដែលបានដាក់បង្ហាញដោយសហព្រះរាជអាជ្ញាអន្តរជាតិមានចំនួនដ៏ច្រើនលើសលប់នាពេលនោះ អង្គជំនុំជម្រះសន្និដ្ឋានថា ការបំពេញការងារដោយយកចិត្តទុកដាក់ត្រូវបានអនុវត្ត ក្នុងការដាក់សំណើនេះ ហេតុនេះការដាក់សំណើនេះនៅតែធ្វើបានទាន់ពេលវេលា។ អង្គជំនុំជម្រះក៏សន្និដ្ឋានផងដែរថា កំណត់ហេតុស្ដាប់ចម្លើយនេះស្របទៅនឹងបទដ្ឋាននៃភាពជឿជាក់ និង យថាភាព *តាមការវិភាគបឋម* ដោយសារឯកសារទាំងនេះបានទទួលពីការិយាល័យសហចៅក្រមស៊ើបអង្កេត (សូមមើល ឯកសារ E319/11/1 កថាខណ្ឌ៥, ឯកសារ E319/17/1 កថាខណ្ឌ៤)។ អង្គជំនុំជម្រះយល់ឃើញថា ចម្លើយដែលមានលេខឯកសារ E319/19.3.226 មានភាពពាក់ព័ន្ធ*តាមការវិភាគបឋម* ដោយសារឯកសារនេះមានព័ត៌មានដែលទាក់ទងទៅនឹងការចាប់ខ្លួនប្រជាជនចាម ដោយសមាជិកក្រុមដាវវែង ដែលមានប្រយោជន៍ក្នុងការស្វែងរកការពិតនៅក្នុងសំណុំរឿង ០០២/០២។

៨. សម្រាប់ចម្លើយដែលនៅសេសសល់ចំនួន ២១ ទៀត ដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ I អង្គជំនុំជម្រះកត់សម្គាល់ថា ឯកសារទាំងនេះបានទទួលដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងអំឡុងដំណាក់កាលស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ និង ០០៤ និងបានចុះកាលបរិច្ឆេទចន្លោះពីខែ សីហា ឆ្នាំ ២០១១ ដល់ខែ ឧសភា ឆ្នាំ ២០១៥។ ឯកសារទាំងនេះអាចរកបាន បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុញ្ញាតឱ្យដាក់បង្ហាញឯកសារទាំងនេះនៅក្នុងសេចក្ដីសម្រេចចំនួនប្រាំបីដែលបានចេញចន្លោះពីខែ កុម្ភៈ ដល់ខែ សីហា ឆ្នាំ ២០១៥ (សំណុំរឿង ០០៤-D193/11, D-193/15, D193/21, D193/24, D193/33, D193-34 សំណុំរឿង ០០៣-D100/9, D-100/12)។ អង្គជំនុំជម្រះសូមរម្លឹកឡើងវិញថា អង្គជំនុំជម្រះរំពឹងថា ភាគីអនុវត្តការបំពេញការងារដោយយកចិត្តទុកដាក់ និងដាក់សំណើសុំឱ្យទទួលយកឯកសារភស្តុតាងឱ្យបានទាន់ពេលវេលាតាមតែអាចធ្វើទៅបាន បន្ទាប់ពីភាគីបាន

ដឹងអំពីអត្ថិភាពនៃឯកសារដែលស្នើសុំឱ្យទទួលយក (ឯកសារ E319/30/1 កថាខណ្ឌ ៣, *សូមមើលផងដែរ* ឯកសារ E344/1 កថាខណ្ឌ ៤, ឯកសារ E323/1)។ នៅក្នុងករណីនេះ ចម្លើយត្រូវបានដាក់បង្ហាញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ (ឯកសារ E319/13) ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៥ (ឯកសារ E319/19) ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៥ (ឯកសារ E319/21) ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៥ (ឯកសារ E319/23) ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៥ (ឯកសារ E319/24) ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៥ (ឯកសារ E319/27) និងថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ (ឯកសារ E319/28) ដែលមានរយៈពេលចន្លោះពីមួយខែ ដល់ប្រាំពីរខែ មុនពេលដាក់សំណើនេះ។ ចំណុចនេះបង្ហាញច្បាស់ថា សហព្រះរាជអាជ្ញាអន្តរជាតិបានបំពេញការងារដោយយកចិត្តទុកដាក់ ក្នុងការស្នើសុំឱ្យទទួលយកចម្លើយទាំងនោះ ដែលអាចរកបាននៅក្នុងសេចក្តីសម្រេចនាពេលថ្មីៗនេះរបស់សហចៅក្រមស៊ើបអង្កេត ជាពិសេសកំណត់ហេតុស្តាប់ចម្លើយទាំងនោះត្រូវបានអនុញ្ញាតឱ្យដាក់បង្ហាញចន្លោះពីខែ មិថុនា ដល់ខែ សីហា ឆ្នាំ ២០១៥។ ដោយពិចារណាដល់ចំនួនច្រើនលើសលប់នៃឯកសារទាំងមូលដែលបានដាក់បង្ហាញ អង្គជំនុំជម្រះក៏សន្និដ្ឋានផងដែរថា ការទទួលយកកំណត់ហេតុស្តាប់ចម្លើយដែលបានដាក់បង្ហាញពីមុននៅក្នុងឆ្នាំ ២០១៥ ត្រូវបានស្នើសុំទាន់ពេលវេលាទៅតាមកាលៈទេសៈទាំងនោះ។

៩. អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា ចម្លើយដែលត្រូវបានស្តាប់ដោយអ្នកស៊ើបអង្កេតពីការិយាល័យសហចៅក្រមស៊ើបអង្កេត បំពេញទៅតាមបទដ្ឋាននៃភាពជឿជាក់ និង យថាភាព *តាមការវិភាគបឋម* (សូមមើល ឯកសារ E319/11/1 កថាខណ្ឌ ៥, ឯកសារ E319/17/1 កថាខណ្ឌ ៤)។

១០. អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យកំណត់ហេតុស្តាប់ចម្លើយដែលនៅសេសសល់ចំនួន ២១ ទៀត ហើយពិចារណាឃើញថា ឯកសារទាំងនេះមានភស្តុតាងដែលពាក់ព័ន្ធនឹងការប្រព្រឹត្តិចំពោះជនជាតិចាម រួមមាន ដោយមិនកម្រិតត្រឹមតែការដាក់ក្នុងមន្ទីរឃុំឃាំង ការបាត់ខ្លួន ការសម្លាប់ប្រជាជនចាមនៅតាមស្រុកនានាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង ពីការចោទប្រកាន់ពីគោលនយោបាយក្នុងការកំណត់ក្រុមនេះជាក្រុមគោលដៅប៉ុណ្ណោះទេ។ ចម្លើយទាំងនេះក៏ទំនងជាពាក់ព័ន្ធនឹងអង្គហេតុផ្សេងទៀតនៃការជំនុំជម្រះផងដែរ រួមមាន ការចេញបទ-

បញ្ហាអំពីការរៀបអាពាហ៍ពិពាហ៍ ការបោសសម្អាតផ្ទៃក្នុង និងការប្រព្រឹត្តិចំពោះជនជាតិវៀតណាម។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសន្និដ្ឋានថា ចម្លើយទាំងនេះមានប្រយោជន៍ក្នុងការស្វែងរកការពិត និងពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ *តាមការវិភាគបឋម*។

១១. ពាក់ព័ន្ធនឹងចម្លើយដែលមានលេខឯកសារ E319/19.3.219 និង E319/19.3.93 ពីសាក្សី 2-TCW-987 អង្គជំនុំជម្រះរម្លឹកថាការជំទាស់របស់មេធាវីការពារក្តី ខៀវ សំផន ក្នុងការស្តាប់សក្ខីកម្មសាក្សីរូបនេះ គឺផ្អែកលើមូលដ្ឋានថា វានឹងរំលោភដល់គោលការណ៍សមភាពនៃមធ្យោបាយតទល់រឿងក្តី និងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានពេលវេលា និងសម្ភារៈគ្រប់គ្រាន់ ដើម្បីរៀបចំការការពារក្តីរបស់ខ្លួន ដោយសារតែការជូនដំណឹងមានភាពយឺតយ៉ាវ ហើយមេធាវីការពារក្តីមិនធ្លាប់ដែលបានដឹងពីបុគ្គលនេះឡើយ មុនពេលខ្លួនបានទទួលដំណឹងថាបុគ្គលនេះត្រូវបានកោះហៅ (ឯកសារ E364 កថាខណ្ឌ ១០)។ អង្គជំនុំជម្រះបានដោះស្រាយការជំទាស់នេះដាច់ដោយឡែក នៅក្នុងសេចក្តីសម្រេចលើការកោះហៅសាក្សីរូបនេះដែលគាត់បានមកផ្តល់សក្ខីកម្មកាលពីថ្ងៃទី ១១ និង ១២ ខែ មករា ឆ្នាំ ២០១៦ (សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ E364/1)។ ជាងនេះទៀត ការជំទាស់នោះពុំមានអានុភាពទៅលើសំណើនេះទេដោយសារសំណើនេះគឺពាក់ព័ន្ធទៅនឹងការទទួលយកចម្លើយទាំងនេះ និងត្រូវបានធ្វើឡើងអនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤)។

១២. ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា លក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងត្រូវបានបំពេញ និងយល់ព្រមតាមសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយចំនួន ២១ ជាឯកសារភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០២។ ចម្លើយទាំងនេះត្រូវបានចាត់ថ្នាក់ជាប្រភេទឯកសារលេខ E3 ដូចមានរៀបរាប់លម្អិតក្នុងឧបសម្ព័ន្ធ ក ភ្ជាប់មកជាមួយអនុស្សរណៈនេះ។ អង្គជំនុំជម្រះរម្លឹកដល់ភាគីថា ការប្រើប្រាស់ចម្លើយទាំងនេះត្រូវស្ថិតទៅតាមលក្ខខណ្ឌតម្រូវផ្នែកនីតិវិធី ដូចមានចែងក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ឯកសារ E319/7 ។

១៣. អនុស្សរណៈនេះជាការឆ្លើយតបផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងឯកសារ E319/32។